ក. បង្ហាញថា $Z_{n+1}=(\cos a+i\sin a)\,Z_n$

យើងមាន $Z_n=U_{n+1}-(\cos a-i\sin a)U_n$

យើងបាន
$$\begin{aligned}Z_{n+1}&=U_{n+2}-(\cos a-i\sin a)U_{n+1}\\&=2U_{n+1}\cos a-U_n-(\cos a-i\sin a)U_{n+1}\\&=(\cos a+i\sin a)U_{n+1}-U_n\\&=(\cos a+i\sin a)(U_{n+1}-\frac{U_n}{\cos a+i\sin a})\\&=(\cos a+i\sin a)\left[U_{n+1}-(\cos a-i\sin a)U_n\right]\\&=(\cos a+i\sin a)\,U_n\end{aligned}$$

ដូចនេះ $Z_{n+1}=(\cos a+i\sin a)\,Z_n$ ។

គណនា Z_n ជាអនុគមន៍នៃ n និង a ៖

ដោយ $Z_{n+1}=(\cos a+i\sin a)\,Z_n$ នាំឲ្យ (Z_n) ជាស្វ៊ីតធរណីមាត្រ

នៃចំនួនកុំផ្លិចដែលមានរេសុង $q=\cos a+i\sin a$ និង តួ $Z_0=U_1-(\cos a-i\sin a)U_0=1$ ។

តាមរូបមន្ត $Z_n=Z_0\times q^n=(\cos a+i\sin a)^n=\cos(na)+i\sin(na)$

ដូចនេះ $Z_n=\cos(na)+i.\sin(na)$ ។

ខ. ទាញរក U_n ជាអនុគមន៍នៃ n ៖

យើងមាន $Z_n=U_{n+1}-(\cos a-i\sin a)U_n$ (1) និង $\overline{Z}_n=U_{n+1}-(\cos a+i\sin a)U_n$ (2)

ដកសមីការ (1) និង (2) អង្គនឹងអង្គគេបាន ៖

$Z_n-\overline{Z}_n=2i\sin a\;U_n$ នាំឲ្យ $U_n=\dfrac{Z_n-\overline{Z}_n}{2i\sin a}$ ដែល $\sin a\neq 0$

ដោយ $Z_n=\cos(na)+i\sin(na)$ និង $\overline{Z}_n=\cos(na)-i\sin(na)$ ។ ដូចនេះ $U_n=\dfrac{\sin(na)}{\sin a}$ ។

លំហាត់ទី៧៤

គេឲ្យ (a_n) ជាស្វ៊ីតនព្វន្តមួយមានផលសងរួម d ។

គេតាង $S_n=\dfrac{\cos a_1}{\cos d}+\dfrac{\cos a_2}{\cos^2 d}+\dfrac{\cos a_3}{\cos^3 d}+...+\dfrac{\cos a_n}{\cos^n d}$ ចំពោះ $n=1,2,3,...$ ។

ចូរស្រាយថា $S_n=\dfrac{\sin a_n}{\cos^n d\sin d}-\dfrac{\sin a_1}{\sin d}$

ដំណោះស្រាយ

ស្រាយថា $S_n=\dfrac{\sin a_n}{\cos^n d\sin d}-\dfrac{\sin a_1}{\sin d}$

ដោយ (a_n) ជាស្វ៊ីតនព្វន្តមួយមានផលសងរួម d នោះ $a_{n+1}=a_n+d$ ។

គេបាន $\sin a_{n+1}=\sin(a_n+d)=\sin a_n\cos d+\sin d\cos a_n$

ចែកអង្គទាំងពីរនឹង $\cos^{n+1} d \neq 0$ គេបាន ៖

$$\frac{\sin a_{n+1}}{\cos^{n+1} d} = \frac{\sin a_n \cos d + \sin d \cos a_n}{\cos^{n+1} d}$$

គេទាញ $\dfrac{\cos a_n}{\cos^n d} = \dfrac{\cos d}{\sin d}\left(\dfrac{\sin a_{n+1}}{\cos^{n+1} d} - \dfrac{\sin a_n}{\cos^n d}\right)$

$$S_n = \sum_{p=1}^{n}\left[\frac{\cos d}{\sin d}\left(\frac{\sin a_{p+1}}{\cos^{p+1} d} - \frac{\sin a_p}{\cos^p d}\right)\right]$$

$$S_n = \frac{\cos d}{\sin d}\left(\frac{\sin a_{n+1}}{\cos^{n+1} d} - \frac{\sin a_1}{\cos d}\right) = \frac{\sin a_{n+1}}{\cos^n d \sin d} - \frac{\sin a_1}{\sin d}$$

ដូចនេះ៖ $S_n = \dfrac{\sin a_n}{\cos^n d \sin d} - \dfrac{\sin a_1}{\sin d}$ ។

លំហាត់ទី៧៥

ចូរគណនាផលបូក $S_n = \dfrac{\tan\frac{\pi}{8}}{\cos\frac{\pi}{4}} + \dfrac{\tan\frac{\pi}{16}}{\cos\frac{\pi}{8}} + \dfrac{\tan\frac{\pi}{32}}{\cos\frac{\pi}{16}} + ... + \dfrac{\tan\frac{\pi}{2^{n+2}}}{\cos\frac{\pi}{2^{n+1}}}$

រួចទាញរកលីមីតនៃ S_n កាលណា $n \to +\infty$ ។

ដំណោះស្រាយ

តាមរូបមន្ត $\tan 2x = \dfrac{2\tan x}{1-\tan^2 x}$ គេបាន $\tan 2x - \tan x = \dfrac{2\tan x}{1-\tan^2 x} - \tan x = \dfrac{\tan x + \tan^2 x}{1-\tan^2 x}$

$\tan 2x - \tan x = \tan x . \dfrac{1+\tan^2 x}{1-\tan^2 x}$ ដោយ $\cos 2x = \dfrac{1-\tan^2 x}{1+\tan^2 x}$

នោះ៖ $\tan 2x - \tan x = \dfrac{\tan x}{\cos 2x}$ (*)

ដោយជ្រើសរើស $x = \dfrac{\pi}{2^{k+2}}$ ជួសក្នុង (*) គេបាន $\tan\dfrac{\pi}{2^{k+1}} - \tan\dfrac{\pi}{2^{k+2}} = \dfrac{\tan\frac{\pi}{2^{k+2}}}{\cos\frac{\pi}{2^{k+1}}}$

យើងបាន $S_n = \displaystyle\sum_{k=1}^{n}\left(\tan\frac{\pi}{2^{k+1}} - \tan\frac{\pi}{2^{k+2}}\right)$

$$= (\tan\frac{\pi}{4} - \tan\frac{\pi}{8}) + (\tan\frac{\pi}{8} - \tan\frac{\pi}{16}) + ... + (\tan\frac{\pi}{2^{n+1}} - \tan\frac{\pi}{2^{n+2}})$$

$$= \tan\frac{\pi}{4} - \tan\frac{\pi}{2^{n+2}} = 1 - \tan\frac{\pi}{2^{n+2}}$$

ដូចនេះ៖ $S_n = 1 - \tan\dfrac{\pi}{2^{n+2}}$ ។ម្យ៉ាងទៀតគេមាន $\lim\limits_{n\to+\infty} \tan\dfrac{\pi}{2^{n+2}} = 0$ ដូចនេះ៖ $\lim\limits_{n\to+\infty} S_n = 1$ ។

លំហាត់ទី៧៦

ក.ចូរបង្ហាញថា $\frac{1}{2+\sin(2n-1)x}-\frac{1}{2+\sin(2n+1)x}=\frac{2\sin x\cos(2nx)}{[2+\sin(2n-1)x\ ][2+\sin(2n+1)x\ ]}$

ខ.គណនា $S_n=\sum_{k=1}^{n}\left[\frac{\cos(2kx)}{\left(2+\sin(2k-1)x\right)\left(2+\sin(2k+1)x\right)}\right]$ ។

ដំណោះស្រាយ

ក. ការបង្ហាញ

តាង $f(x)=\frac{1}{2+\sin(2n-1)x}-\frac{1}{2+\sin(2n+1)x}$

$$=\frac{\sin(2n+1)x-\sin(2n-1)x}{\left(2+\sin(2n-1)x\right)\left(2+\sin(2n+1)x\right)}=\frac{2\sin x\ \cos(2nx)}{\left(2+\sin(2n-1)x\right)\left(2+\sin(2n+1)x\right)}$$

ខ.គណនា $S_n=\sum_{k=1}^{n}\left[\frac{\cos(2kx)}{\left(2+\sin(2k-1)x\right)\left(2+\sin(2k+1)x\right)}\right]$

យើងបាន $S_n=\frac{1}{2\sin x}\sum_{k=1}^{n}\left[\frac{1}{2+\sin(2n-1)x}-\frac{1}{2+\sin(2n+1)x}\right]$

$$=\frac{1}{2\sin x}\left[\frac{1}{2+\sin x}-\frac{1}{2+\sin(2n+1)x}\right]=\frac{1}{2\sin x}.\frac{\sin(2n+1)x-\sin x}{\left(2+\sin x\right)\left(2+\sin(2n+1)x\right)}$$

$$=\frac{\sin(nx)\cos(n+1)x}{\sin x\left(2+\sin x\right)(2+\sin(2n+1)x)}$$

ដូចនេះ $S_n=\frac{\sin(nx)\cos(n+1)x}{\sin x\left(2+\sin x\right)(2+\sin(2n+1)x)}$ ។

លំហាត់ទី៧៧

ក.ចូរស្រាយថា $\cos(2nx)=\frac{1}{2\sin x}[\ \sin(2n+1)x-\sin(2n-1)x\ ]$

ខ.គណនាផលបូក $S_n=\cos 2x+\cos 4x+\cos 6x+.....+\cos(2nx)$

គ.ទាញរកផលបូក $T_n=\cos^2 x+\cos^2 2x+\cos^2 3x+.....+\cos^2(nx)$

ឃ.គណនាផលបូក $U_n=\sin^2 x+\sin^2 2x+\sin^2 3x+.....+\sin^2(nx)$

ដំណោះស្រាយ

ក.ស្រាយថា $\cos(2nx)=\frac{1}{2\sin x}[\ \sin(2n+1)x-\sin(2n-1)x\ ]$

តាមរូបមន្ត $\sin p-\sin q=2\sin(\frac{p-q}{2})\ \cos(\frac{p+q}{2})$ ដោយយក $p=(2n+1)x$, $q=(2n-1)x$

និង $p-q=2x$, $p+q=4nx$ គេបាន $\sin(2n+1)x-\sin(2n-1)x=2\sin x\ \cos(2nx)$

ដូចនេះ $\cos(2nx)=\frac{1}{2\sin x}[\ \sin(2n+1)x-\sin(2n-1)x\ ]$ ។

ខ.គណនាផលបូក $S_n=\cos 2x+\cos 4x+\cos 6x+.....+\cos(2nx)$

យើងបាន $S_n = \sum_{k=1}^{n}[\cos(2kx)]$

$$= \frac{1}{2\sin x}\sum_{k=1}^{n}[\sin(2k+1)x - \sin(2k-1)x]$$

$$= \frac{1}{2\sin x}[\sin(2n+1)x - \sin x]$$

$$= \frac{1}{2\sin x}[2\sin(nx)\cos(n+1)x] = \frac{\sin(nx)\,\cos(n+1)x}{\sin x}$$

ដូចនេះ $S_n = \dfrac{\sin(nx)\cos(n+1)x}{\sin x}$ ។

គ.ទាញរកផលបូក $T_n = \cos^2 x + \cos^2 2x + \cos^2 3x + ... + \cos^2(nx)$

យើងបាន $T_n = \sum_{k=1}^{n}\left[\cos^2(kx)\right]$ តាមរូបមន្ត $\cos^2 a = \dfrac{1+\cos 2a}{2}$

គេបាន $T_n = \sum_{k=1}^{n}\left[\dfrac{1+\cos(2kx)}{2}\right] = \dfrac{n}{2} + \dfrac{1}{2}S_n$ ដោយ $S_n = \dfrac{\sin(nx)\cos(n+1)x}{\sin x}$

ដូចនេះ $T_n = \dfrac{n}{2} + \dfrac{\sin(nx)\cos(n+1)x}{2\sin x}$ ។

ឃ.គណនាផលបូក

$U_n = \sin^2 x + \sin^2 2x + \sin^2 3x + ... + \sin^2(nx)$

យើងបាន $U_n = \sum_{k=1}^{n}\left[\sin^2(kx)\right] = \sum_{k=1}^{n}\left[1-\cos^2(kx)\right] = n - T_n$ ដោយ $T_n = \dfrac{n}{2} + \dfrac{\sin(nx)\cos(n+1)x}{2\sin x}$

ដូចនេះ $U_n = \dfrac{n}{2} - \dfrac{\sin(nx)\cos(n+1)x}{2\sin x}$ ។

លំហាត់ទី៧៨

ក. ចូរស្រាយបញ្ជាក់ទំនាក់ទំនង $\tan x = \cot x - 2\cot 2x$

ខ. ចូរគណនាផលបូក $S_n = \tan a + \dfrac{1}{2}\tan\dfrac{a}{2} + \dfrac{1}{2^2}\tan\dfrac{a}{2^2} + ... + \dfrac{1}{2^n}\tan\dfrac{a}{2^n}$

ដំណោះស្រាយ

ក. ស្រាយបញ្ជាក់ទំនាក់ទំនង $\tan x = \cot x - 2\cot 2x$

តាង $A = \cot x - 2\cot 2x$

ដោយ $\begin{cases} \cot x = \dfrac{1}{\tan x} \\ \cot 2x = \dfrac{1}{\tan 2x} = \dfrac{1-\tan^2 x}{2\tan x} \end{cases}$

គេបាន $A = \dfrac{1}{\tan x} - 2\left(\dfrac{1-\tan^2 x}{2\tan x}\right) = \dfrac{1-1+\tan^2 x}{\tan x} = \tan x$

ដូចនេះ $\tan x = \cot x - 2\cot 2x$ ។

ខ. គណនាផលបូក

$$S_n = \tan a + \frac{1}{2}\tan\frac{a}{2} + \frac{1}{2^2}\tan\frac{a}{2^2} + ... + \frac{1}{2^n}\tan\frac{a}{2^n}$$

$$= \sum_{k=0}^{n}\left(\frac{1}{2^k}\tan\frac{a}{2^k}\right) = \sum_{k=0}^{n}\left[\frac{1}{2^k}(\cot\frac{a}{2^k} - 2\cot\frac{a}{2^{k-1}})\right] = \sum_{k=0}^{n}\left(\frac{1}{2^k}\cot\frac{a}{2^k} - \frac{1}{2^{k-1}}\cot\frac{a}{2^{k-1}}\right) = \frac{1}{2^n}\cot\frac{a}{2^n} - 2\cot 2a$$

ដូចនេះ $S_n = \tan a + \frac{1}{2}\tan\frac{a}{2} + ... + \frac{1}{2^n}\tan\frac{a}{2^n} = \frac{1}{2^n}\cot\frac{a}{2^n} - 2\cot 2a$

លំហាត់ទី៧៩

គណនាផលគុណខាងក្រោម ៖

$$P_n = \prod_{k=0}^{n}\left(\tan^{2^k}\frac{x}{2^k}\right) = \tan x.\tan^2\frac{x}{2}.\tan^4\frac{x}{4}.....\tan^{2^n}\frac{x}{2^n}\ \lim_{x\to\infty}$$

ដំណោះស្រាយ

គណនាផលគុណ P_n

គេមាន $\tan a = \frac{\sin a}{\cos a} = \frac{2\sin^2 a}{2\sin a\cos a} = \frac{2\sin^2 a}{\sin 2a}$ យក $a = \frac{x}{2^k}$ គេបាន $\tan\frac{x}{2^k} = \frac{2\sin^2\frac{x}{2^k}}{\sin\frac{2x}{2^k}}$

គេទាញ $P_n = \prod_{k=0}^{n}\left(2^{2^k}.\frac{\sin^{2^{k+1}}\frac{x}{2^k}}{\sin^{2^k}\frac{2x}{2^k}}\right) = 2^{2^{n+1}-1}.\frac{\sin^{2^{n+1}}\frac{x}{2^n}}{\sin 2x}$

ដូចនេះ $P_n = 2^{2^{n+1}-1}.\frac{\sin^{2^{n+1}}\frac{x}{2^n}}{\sin 2x}$ ។

លំហាត់ទី៨០

គណនាផលគុណ $P_n = \prod_{k=0}^{n}\left[(1-\tan^2\frac{x}{2^k})^{2^k}\right]$

ដំណោះស្រាយ

គណនាផលគុណ $P_n = \prod_{k=0}^{n}\left[(1-\tan^2\frac{x}{2^k})^{2^k}\right]$

យើងមាន $1-\tan^2\frac{x}{2^k} = \frac{\cos^2\frac{x}{2^k} - \sin^2\frac{x}{2^k}}{\cos^2\frac{x}{2^k}} = \frac{\cos\frac{2x}{2^k}}{\cos^2\frac{x}{2^k}}$

គេបាន $P_n = \prod_{k=0}^{n}\left[\frac{\cos^{2^k}\frac{x}{2^{k-1}}}{\cos^{2^{k+1}}\frac{x}{2^k}}\right] = \frac{\cos 2x}{\cos^{2^{n+1}}\frac{x}{2^n}}$

ដូចនេះ $P_n = \frac{\cos 2x}{\cos^{2^{n+1}}\frac{x}{2^n}}$ ។

លំហាត់ទី៨១

គណនាផលគុណ៖

$$P_n=\prod_{k=1}^{n}\left[\frac{1+\tan^2 2^k x}{\left(1-\tan^2 2^k\right)^2}\right] \quad \text{ដែល } |x|<\frac{\pi}{2^{n+2}}$$

ដំណោះស្រាយ

តាមរូបមន្ត $\cos 2a=\dfrac{1-\tan^2 a}{1+\tan^2 a}$ គេបាន $\cos 2^{k+1}x=\dfrac{1-\tan^2 2^k x}{1+\tan^2 2^k x}$

ហើយ $1-\tan^2 2^k=\dfrac{\cos^2 2^k-\sin^2 2^k}{\cos^2 2^k x}=\dfrac{\cos 2^{k+1}x}{\cos^2 2^k x}$

គេបាន $\dfrac{1+\tan^2 2^k x}{(1-\tan^2 2^k x)^2}=\dfrac{\cos^2 2^k x}{\cos^2 2^{k+1}x}$

ដូចនេះ៖ $P_n=\prod_{k=1}^{n}\left(\dfrac{\cos^2 2^k x}{\cos^2 2^{k+1}x}\right)=\dfrac{\cos^2 2x}{\cos^2 2^{n+1}x}$ ។

លំហាត់ទី៨២

ក.ចូរស្រាយថា $\dfrac{1}{\sin 2x}=\cot x-\cot 2x$

ខ.ចូរគណនា $S_n=\dfrac{1}{\sin a}+\dfrac{1}{\sin\frac{a}{2}}+\dfrac{1}{\sin\frac{a}{2^2}}+....+\dfrac{1}{\sin\frac{a}{2^n}}$

ដំណោះស្រាយ

ក.ស្រាយថា $\dfrac{1}{\sin 2x}=\cot x-\cot 2x$

តាង $f(x)=\cot x-\cot 2x$

$$=\frac{\cos x}{\sin x}-\frac{\cos 2x}{\sin 2x}=\frac{\cos x}{\sin x}-\frac{2\cos^2 x-1}{2\sin x\cos x}$$

$$=\frac{2\cos^2 x-2\cos^2 x+1}{2\sin x\cos x}=\frac{1}{\sin 2x}$$

ដូចនេះ៖ $\dfrac{1}{\sin 2x}=\cot x-\cot 2x$ ។

ខ.គណនា $S_n=\dfrac{1}{\sin a}+\dfrac{1}{\sin\frac{a}{2}}+\dfrac{1}{\sin\frac{a}{2^2}}+....+\dfrac{1}{\sin\frac{a}{2^n}}$

យើងបាន $S_n=\sum_{k=0}^{n}\left(\dfrac{1}{\sin\frac{a}{2^k}}\right)$ ដោយ $\dfrac{1}{\sin 2x}=\cot x-\cot 2x$

$$S_n=\sum_{k=0}^{n}\left(\cot\frac{a}{2^{k+1}}-\cot\frac{a}{2^k}\right)=\cot\frac{a}{2^{n+1}}-\cot a$$

ដូចនេះ៖ $S_n=\cot\dfrac{a}{2^{n+1}}-\cot a$ ។

លំហាត់ទី៨៣

ក.ចូរស្រាយថា $1+\frac{1}{\cos x}=\frac{\cot\frac{x}{2}}{\cot x}$

ខ.គណនា $P_n=(1+\frac{1}{\cos a})(1+\frac{1}{\cos\frac{a}{2}})(1+\frac{1}{\cos\frac{a}{2^2}}).....(1+\frac{1}{\cos\frac{a}{2^n}})$

ដំណោះស្រាយ

ក.ស្រាយថា $1+\frac{1}{\cos x}=\frac{\cot\frac{x}{2}}{\cot x}$

យើងតាង $A(x)=1+\frac{1}{\cos x}$

$$=\frac{\cos x+1}{\cos x}=\frac{2\cos^2\frac{x}{2}}{\cos x}=\frac{2\cos^2\frac{x}{2}\sin\frac{x}{2}}{\cos x\sin\frac{x}{2}}=\frac{\cos\frac{x}{2}\sin x}{\cos x\sin\frac{x}{2}}$$

$$=\frac{\cos\frac{x}{2}}{\sin\frac{x}{2}}.\frac{\sin x}{\cos x}=\tan\frac{x}{2}\ \tan x=\frac{\cot\frac{x}{2}}{\cot x}$$

ដូចនេះ $1+\frac{1}{\cos x}=\frac{\cot\frac{x}{2}}{\cot x}$ ៗ

ខ.គណនាផលគុណ

$$P_n=(1+\frac{1}{\cos a})(1+\frac{1}{\cos\frac{a}{2}})(1+\frac{1}{\cos\frac{a}{2^2}}).....(1+\frac{1}{\cos\frac{a}{2^n}})$$

$$=\prod_{k=0}^{n}\left(1+\frac{1}{\cos\frac{a}{2^k}}\right)=\prod_{k=0}^{n}[\frac{\cot\frac{a}{2^{k+1}}}{\cot\frac{a}{2^k}}]$$

ដូចនេះ $P_n=\tan\frac{a}{2^{n+1}}.\cot a$ ៗ

លំហាត់ទី៨៤

ក.ចូរស្រាយថា $\sin^3 x=\frac{1}{4}(\ 3\sin x-\sin 3x)$

ខ.ចូរគណនា

$$S_n=\sin^3\frac{a}{3}+3\sin^3\frac{a}{3^2}+3^2\sin^3\frac{a}{3^3}+....+3^{n-1}\sin^3\frac{a}{3^n}$$

ដំណោះស្រាយ

ក.ស្រាយថា $\sin^3 x = \frac{1}{4}(\,3\sin x - \sin 3x)$

យើងមាន $\sin 3x = \sin(x + 2x)$

តាមរូបមន្ត $\sin(a+b) = \sin a\cos b + \sin b\cos a$

$$= \sin x\cos 2x + \sin 2x\cos x$$

$$= \sin x(1-2\sin^2 x) + 2\sin x\cos^2 x = \sin x(1-2\sin^2 x) + 2\sin x(1-\sin^2 x)$$

$$= \sin x - 2\sin^3 x + 2\sin x - 2\sin^3 x = 3\sin x - 4\sin^3 x$$

ដោយ $\sin 3x = 3\sin x - 4\sin^3 x$

ដូចនេះ $\sin^3 x = \frac{1}{4}(\,3\sin x - \sin 3x)$ ។

ខ. គណនា $S_n = \sin^3\frac{a}{3} + 3\sin^3\frac{a}{3^2} + 3^2\sin^3\frac{a}{3^3} + ... + 3^{n-1}\sin^3\frac{a}{3^n}$

យើងបាន $S_n = \sum_{k=1}^{n}\left(3^{k-1}\sin^3\frac{a}{3^k}\right)$

ដោយ$\sin^3 x = \frac{1}{4}(\,3\sin x - \sin 3x)$

$S_n = \frac{1}{4}\sum_{k=1}^{n}\left(3^k\sin\frac{a}{3^k} - 3^{k-1}\sin\frac{a}{3^{k-1}}\right) = \frac{1}{4}(3^n\sin\frac{a}{3^n} - \sin a)$ ។

លំហាត់ទី៨៥

ក.ចូរស្រាយបញ្ជាក់ថា $\tan 2x.\tan^2 x = \tan 2x - 2\tan x$

ខ.ចូរគណនាផលបូក $S_n = \sum_{k=0}^{n}\left[2^k\tan\frac{a}{2^k}\tan^2\frac{a}{2^{k+1}}\right]$

ដំណោះស្រាយ

ក.ស្រាយបញ្ជាក់ថា $\tan 2x.\tan^2 x = \tan 2x - 2\tan x$

តាង $f(x) = \tan 2x - 2\tan x$ ដោយ $\tan 2x = \frac{2\tan x}{1-\tan^2 x}$

គេបាន $f(x) = \frac{2\tan x}{1-\tan^2 x} - 2\tan x$

$$= \frac{2\tan x - 2\tan x(1-\tan^2 x)}{1-\tan^2 x} = \frac{2\tan x - 2\tan x + 2\tan^3 x}{1-\tan^2 x}$$

$$= \frac{2\tan^3 x}{1-\tan^2 x} = \frac{2\tan x}{1-\tan^2 x}.\tan^2 x = \tan 2x.\tan^2 x$$

ដូចនេះ $\tan 2x.\tan^2 x = \tan 2x - 2\tan x$ ។

ខ.គណនាផលបូក $S_n = \sum_{k=0}^{n}\left[2^k\tan\frac{a}{2^k}\tan^2\frac{a}{2^{k+1}}\right]$

យើងមាន $\tan 2x.\tan^2 x = \tan 2x - 2\tan x$ ដោយយក $x = \frac{a}{2^{k+1}}$

គេបាន $\tan\frac{a}{2^k}\tan^2\frac{a}{2^{k+1}} = \tan\frac{a}{2^k} - 2\tan\frac{a}{2^{k+1}}$

$$S_n = \sum_{k=0}^{n}\left(2^k \tan\frac{a}{2^k} - 2^{k+1}\tan\frac{a}{2^{k+1}}\right) = \tan a - 2^{n+1}\tan\frac{a}{2^{n+1}}$$

ដូចនេះ $S_n = \sum_{k=0}^{n}\left[2^k \tan\frac{a}{2^k}\ \tan^2\frac{a}{2^{k+1}}\right] = \tan a - 2^{n+1}\tan\frac{a}{2^{n+1}}$ ។

លំហាត់ទី៨៦

គេឱ្យត្រីកោណ ABC មួយ ។

ក. ចូរស្រាយបញ្ជាក់ថា $1-\cos A \le \frac{a^2}{2bc}$ ដែល a , b , c ជាជ្រុងត្រីកោណ ABC ។

ខ. ទាញបញ្ជាក់ថា $(1-\cos A)(1-\cos B)(1-\cos C) \le \frac{1}{8}$

ដំណោះស្រាយ

ក.ស្រាយបញ្ជាក់ថា $1-\cos A \le \frac{a^2}{2bc}$

តាមទ្រឹស្តីបទស៊ីនូសគេមាន $a^2 = b^2 + c^2 - 2bc\cos A$

តាមវិសមភាពមធ្យមនព្វន្ត មធ្យមធរណីមាត្រគេមាន $b^2 + c^2 \ge 2bc$

គេទាញ $a^2 \ge 2bc - 2bc\cos A = 2bc(1-\cos A)$

ដូចនេះ $1-\cos A \le \frac{a^2}{2bc}$ ។

ខ. ទាញបញ្ជាក់ថា $(1-\cos A)(1-\cos B)(1-\cos C) \le \frac{1}{8}$

តាមសម្រាយខាងលើគេមាន $1-\cos A \le \frac{a^2}{2bc}$ (1)

ស្រាយដូចគ្នាដែរ $1-\cos B \le \frac{b^2}{2ac}$ (2) និង $1-\cos C \le \frac{c^2}{2ab}$ (3)

គុណវិសមភាព (1) , (2) , (3) អង្គ និង អង្គគេទទួលបាន ៖

$(1-\cos A)(1-\cos B)(1-\cos C) \le \frac{1}{8}$ ពិត ។

លំហាត់ទី៨៧

គេឱ្យត្រីកោណ ABC មួយ ។

ក. ចូរស្រាយបញ្ជាក់ថា $\sin^2 A = \sin^2 B + \sin^2 C - 2\sin B\sin C\cos A$

ខ. ទាញបញ្ជាក់ថា ៖

$$\cot A + \cot B + \cot C = \frac{\sin^2 A + \sin^2 B + \sin^2 C}{2\sin A\sin B\sin C}$$

ដំណោះស្រាយ

ក.ស្រាយបញ្ជាក់ថា $\sin^2 A = \sin^2 B + \sin^2 C - 2\sin B\sin C\cos A$

តាង a , b , c ជាជ្រុងត្រីកោណ ABC និង R ជាកាំរង្វង់ចារឹកក្រៅត្រីកោណ។

តាមទ្រឹស្តីបទស៊ីនូស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=2R$

គេទាញ $\begin{cases} a=2R\sin A \\ b=2r\sin B \quad (1) \\ c=2R\sin C \end{cases}$

តាមទ្រឹស្តីបទកូស៊ីនូស $a^2=b^2+c^2-2bc\cos A \quad (2)$

យក (1) ជំនួសក្នុង (2) គេបាន ៖

$4R^2\sin^2 A=4R^2(\sin^2 B+\sin^2 C-2\sin B\sin C\cos A)$

សម្រួល $4R^2$ ក្នុងអង្គទាំងពីរនៃសមភាពគេបាន $\sin^2 A=\sin^2 B+\sin^2 C-2\sin B\sin C\cos A$ ពិត

ដូចនេះ $\sin^2 A=\sin^2 B+\sin^2 C-2\sin B\sin C\cos A$ ។

ខ. ទាញបញ្ជាក់ថា ៖

$$\cot A+\cot B+\cot C=\frac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C}$$

តាមសម្រាយខាងលើគេមាន $\sin^2 A=\sin^2 B+\sin^2 C-2\sin B\sin C\cos A$

គេទាញ $\cos A=\frac{\sin^2 B+\sin^2 C-\sin^2 A}{2\sin B\sin C}$ ដោយ $\cot A=\frac{\cos A}{\sin A}$

គេបាន $\cot A=\frac{\sin^2 B+\sin^2 C-\sin^2 A}{2\sin A\sin B\sin C} \quad (i)$

ស្រាយដូចគ្នាដែរគេទទួលបាន $\cot B=\frac{\sin^2 A+\sin^2 C-\sin^2 B}{2\sin A\sin B\sin C} \quad (ii)$

និង $\cot C=\frac{\sin^2 A+\sin^2 B-\sin^2 C}{2\sin A\sin B\sin C} \quad (iii)$

ធ្វើផលបូកសមភាព (i) , (ii) & (iii) គេបាន ៖

$$\cot A+\cot B+\cot C=\frac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C} \quad \text{ពិត}$$

ដូចនេះ $\cot A+\cot B+\cot C=\frac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C}$ ។

លំហាត់ទី៨៨

ក.ចូរស្រាយថា $\frac{\tan^3 x}{1-\tan^2 x}=\frac{1}{2}\tan 2x-\tan x$

ខ.ចូរគណនាផលបូក $S_n=\sum_{k=0}^{n}\left(\frac{2^k\tan^3\frac{a}{2^n}}{1-\tan^2\frac{a}{2^n}}\right)$

ដំណោះស្រាយ

ក.ស្រាយថា $\frac{\tan^3 x}{1-\tan^2 x}=\frac{1}{2}\tan 2x-\tan x$

យើងបាន $\frac{1}{2}\tan 2x-\tan x=\frac{\tan x}{1-\tan^2 x}-\tan x=\frac{\tan^3 x}{1-\tan^2 x}$

ដូចនេះ $\dfrac{\tan^3 x}{1-\tan^2 x}=\dfrac{1}{2}\tan 2x-\tan x$ ។

ខ.គណនាផលបូក $S_n=\sum\limits_{k=0}^{n}\left(\dfrac{2^k\tan^3\frac{a}{2^k}}{1-\tan^2\frac{a}{2^k}}\right)$

គេមាន $\dfrac{\tan^3 x}{1-\tan^2 x}=\dfrac{1}{2}\tan 2x-\tan x$ យក $x=\dfrac{a}{2^k}$ គេបាន $\dfrac{\tan^3\frac{a}{2^k}}{1-\tan^2\frac{a}{2^k}}=\dfrac{1}{2}\tan\dfrac{a}{2^{k-1}}-\tan\dfrac{a}{2^k}$

យើងបាន $S_n=\sum\limits_{k=0}^{n}\left(2^{k-1}\tan\dfrac{a}{2^{k-1}}-2^k\tan\dfrac{a}{2^k}\right)=\dfrac{1}{2}\tan 2a-2^n\tan\dfrac{a}{2^n}$ ។

ដូចនេះ $S_n=\dfrac{1}{2}\tan 2a-2^n\tan\dfrac{a}{2^n}$ ។

លំហាត់ទី៨៩

ត្រីកោណ ABC មួយមានជ្រុង a,b,c ។ ចូរស្រាយថា $\dfrac{a^2}{bc}+\dfrac{b^2}{ca}+\dfrac{c^2}{ab}\geq 4\left(\sin^2\dfrac{A}{2}+\sin^2\dfrac{B}{2}+\sin^2\dfrac{C}{2}\right)$

ដំណោះស្រាយ

ស្រាយថា $\dfrac{a^2}{bc}+\dfrac{b^2}{ca}+\dfrac{c^2}{ab}\geq 4\left(\sin^2\dfrac{A}{2}+\sin^2\dfrac{B}{2}+\sin^2\dfrac{C}{2}\right)$

តាមទ្រឹស្តីបទស៊ីនូស $a^2=b^2+c^2-2bc\cos A$

ដោយ $b^2+c^2\geq 2bc$ នោះ $a^2\geq 2bc-2bc\cos A=4bc\sin^2\dfrac{A}{2}$ គេទាញ $\dfrac{a^2}{bc}\geq 4\sin^2\dfrac{A}{2}$ (1)

ស្រាយដូចគ្នា $\dfrac{b^2}{ac}\geq 4\sin^2\dfrac{B}{2}$ (2) និង $\dfrac{c^2}{ab}\geq 4\sin^2\dfrac{C}{2}$ (3)

បូកវិសមភាព (1) , (2) និង (3) អង្គ និងអង្គគេបាន $\dfrac{a^2}{bc}+\dfrac{b^2}{ca}+\dfrac{c^2}{ab}\geq 4\left(\sin^2\dfrac{A}{2}+\sin^2\dfrac{B}{2}+\sin^2\dfrac{C}{2}\right)$ ។

លំហាត់ទី៩០

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\dfrac{\cos A}{a^3}+\dfrac{\cos B}{b^3}+\dfrac{\cos C}{c^3}\geq\dfrac{3}{2abc}$ ។

ដំណោះស្រាយ

ស្រាយថា $\dfrac{\cos A}{a^3}+\dfrac{\cos B}{b^3}+\dfrac{\cos C}{c^3}\geq\dfrac{3}{2abc}$ ។ ។

តាមទ្រឹស្តីបទស៊ីនូស $a^2=b^2+c^2-2bc\cos A$

គេទាញបាន $\dfrac{2bc\cos A}{a^2}+1=\dfrac{b^2}{a^2}+\dfrac{c^2}{a^2}\geq\dfrac{2bc}{a^2}$ (1)

ស្រាយដូចគ្នាដែរ $\dfrac{2ac\cos B}{b^2}+1\geq\dfrac{2ac}{b^2}$ (2) និង $\dfrac{2ab\cos C}{c^2}+1\geq\dfrac{2ab}{c^2}$ (3)

បូក (1),(2)និង(3)គេបាន ៖

$$\frac{2bc\cos A}{a^2}+\frac{2ca\cos B}{b^2}+\frac{2ab\cos C}{c^2}+3\geq 2\left(\frac{bc}{a^2}+\frac{ac}{b^2}+\frac{ab}{c^2}\right)\geq 6$$

គេទាញ $\frac{\cos A}{a^3}+\frac{\cos B}{b^3}+\frac{\cos C}{c^3}\geq\frac{3}{2abc}$ ។

លំហាត់ទី៩១

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}\leq\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}$

ដំណោះស្រាយ

តាមទ្រឹស្តីបទស៊ីនូស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}$

គេបាន $\frac{a}{b+c}=\frac{\sin A}{\sin B+\sin C}=\frac{2\sin\frac{A}{2}\cos\frac{A}{2}}{2\sin\frac{B+C}{2}\cos\frac{B-C}{2}}$

ដោយ $\sin\frac{B+C}{2}=\sin\left(\frac{\pi}{2}-\frac{A}{2}\right)=\cos\frac{A}{2}$ និង $\cos\frac{B-C}{2}\leq 1$ គេទាញបាន $\frac{a}{b+c}\geq\sin\frac{A}{2}$ ។

ស្រាយដូចគ្នាដែរ $\frac{b}{c+a}\geq\sin\frac{B}{2}$ និង $\frac{c}{a+b}\geq\sin\frac{C}{2}$ ។

ដូចនេះ $\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}\leq\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}$ ពិត

លំហាត់ទី៩២

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\frac{a-b}{a+b}=\tan\frac{A-B}{2}\tan\frac{C}{2}$ រួចសរសេររូបមន្តពីរ ទៀតដែលស្រដៀងគ្នានេះ ។

ដំណោះស្រាយ

តាមទ្រឹស្តីបទស៊ីនូស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}$

គេបាន $\frac{a-b}{a+b}=\frac{\sin A-\sin B}{\sin A+\sin B}=\frac{2\sin\frac{A-B}{2}\cos\frac{A+B}{2}}{2\sin\frac{A+B}{2}\cos\frac{A-B}{2}}$ ដោយ $\sin\frac{A+B}{2}=\cos\frac{C}{2}$ និង $\cos\frac{A+B}{2}=\sin\frac{C}{2}$

ដូចនេះ $\frac{a-b}{a+b}=\tan\frac{A-B}{2}\tan\frac{C}{2}$ ។

ដូចគ្នាដែរ $\frac{b-c}{b+c}=\tan\frac{B-C}{2}\tan\frac{A}{2}$ និង $\frac{c-a}{c+a}=\tan\frac{C-A}{2}\tan\frac{B}{2}$ ។

លំហាត់ទី៩៣

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\sin\frac{A}{2}\leq\frac{a}{2\sqrt{bc}}$ រួចទាញថា $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}\leq\frac{1}{8}$

ដំណោះស្រាយ

តាមទ្រឹស្តីបទស៊ីនូស $a^2 = b^2 + c^2 - 2bc\cos A$

ដោយ $b^2 + c^2 \ge 2bc$ នោះ $a^2 \ge 2bc - 2bc\cos A = 4bc\sin^2\frac{A}{2}$ ឬ $\sin^2\frac{A}{2} \le \frac{a^2}{4bc}$

ដូចនេះ $\sin\frac{A}{2} \le \frac{a}{2\sqrt{bc}}$ ។

ស្រាយដូចគ្នាដែរ $\sin\frac{B}{2} \le \frac{b}{2\sqrt{ac}}$ និង $\sin\frac{C}{2} \le \frac{c}{2\sqrt{ab}}$

គេបាន $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2} \le \frac{a}{2\sqrt{bc}}.\frac{b}{2\sqrt{ac}}.\frac{c}{2\sqrt{ab}} = \frac{1}{8}$

ដូចនេះ $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2} \le \frac{1}{8}$ ។

លំហាត់ទី៩៤

គេឲ្យ α, β, γ ជាបីចំនួនពិតដែល $\sin\alpha + \sin\beta + \sin\gamma \ge \frac{3}{2}$

ចូរស្រាយថា $\sin(\alpha - \frac{\pi}{6}) + \sin(\beta - \frac{\pi}{6}) + \sin(\gamma - \frac{\pi}{6}) \ge 0$ ។

ដំណោះស្រាយ

ស្រាយថា $\sin(\alpha - \frac{\pi}{6}) + \sin(\beta - \frac{\pi}{6}) + \sin(\gamma - \frac{\pi}{6}) \ge 0$

យើងឧបមាថា $\sin(\alpha - \frac{\pi}{6}) + \sin(\beta - \frac{\pi}{6}) + \sin(\gamma - \frac{\pi}{6}) < 0$ ពិត

សមមូល $\frac{\cos\alpha + \cos\beta + \cos\gamma}{2} > \frac{\sqrt{3}}{2}(\sin\alpha + \sin\beta + \sin\gamma)$ ដោយ $\sin\alpha + \sin\beta + \sin\gamma \ge \frac{3}{2}$

នោះ $\frac{\cos\alpha + \cos\beta + \cos\gamma}{2} > \frac{3\sqrt{3}}{4}$ គេទាញ $\cos\alpha + \cos\beta + \cos\gamma > \frac{3\sqrt{3}}{2}$ ។

ពិនិត្យ $T = \sin(\alpha + \frac{\pi}{3}) + \sin(\beta + \frac{\pi}{3}) + \sin(\gamma + \frac{\pi}{3})$

$$= \frac{\sin\alpha + \sin\beta + \sin\gamma}{2} + \frac{\sqrt{3}(\cos\alpha + \cos\beta + \cos\gamma)}{2}$$

ដោយ $\sin\alpha + \sin\beta + \sin\gamma \ge \frac{3}{2}$ និង $\cos\alpha + \cos\beta + \cos\gamma > \frac{3\sqrt{3}}{2}$

គេទាញ $T > \frac{3}{4} + \frac{9}{4} = 3$ មិនពិត ព្រោះគ្រប់ចំនួនពិត α, β, γ

គេមាន $T = \sin(\alpha + \frac{\pi}{3}) + \sin(\beta + \frac{\pi}{3}) + \sin(\gamma + \frac{\pi}{3}) \le 1 + 1 + 1 = 3$ នាំឲ្យការឧបមាខាងលើខុស ។

ដូចនេះ $\sin(\alpha - \frac{\pi}{6}) + \sin(\beta - \frac{\pi}{6}) + \sin(\gamma - \frac{\pi}{6}) \ge 0$ ។

លំហាត់ទី៩៥

គេឲ្យ α និង β ជាពីរចំនួនពិតនៃចន្លោះ $\left[0,\frac{\pi}{2}\right]$ ។

ចូរបង្ហាញថា $\sin^6\alpha+3\sin^2\alpha\cos^2\beta+\cos^6\beta=1$ លុះត្រាតែ $\alpha=\beta$ ។

ដំណោះស្រាយ

តាងសំណើ p : $\sin^6\alpha+3\sin^2\alpha\cos^2\beta+\cos^6\beta=1$

$q:\alpha=\beta$ ។ ដើម្បីស្រាយថា $p\Leftrightarrow q$ ពិត

យើងត្រូវស្រាយថា $p\Rightarrow q$ ពិត និង $q\Rightarrow p$ ពិត ។

យើងស្រាយថា $p\Rightarrow q$ ពិត ៖

តាម $\sin^6\alpha+3\sin^2\alpha\cos^2\beta+\cos^6\beta=1$ គេអាចសរសេរ ៖

$$\left(\sin^2\alpha\right)^3+\left(\cos^2\beta\right)^3+(-1)^3-3\left(\sin^2\alpha\right)\left(\cos^2\beta\right)(-1)=0$$

ដោយប្រើសមភាព $a^3+b^3+c^3-3abc=\frac{1}{2}(a+b+c)\left[(a-b)^2+(b-c)^2+(c-a)^2\right]$

បើគេយក $a=\sin^2\alpha$, $b=\cos^2\beta$, $c=-1$ នោះគេបាន ៖

$$\left[\begin{array}{ll} a+b+c=0 & (1) \\ (a-b)^2+(b-c)^2+(c-a)^2=0 & (2) \end{array}\right.$$

តាម (2) គេទាញ $a=b=c$ ឬ $\sin^2\alpha=\cos^2\beta=-1$ (មិនអាច)

តាម(1)គេបាន $\sin^2\alpha+\cos^2\beta-1=0$

ឬ $\sin^2\alpha=1-\cos^2\beta=\sin^2\beta$ ដោយ $\alpha,\beta\in\left[0,\frac{\pi}{2}\right]$ នោះ $\alpha=\beta$ ។

យើងស្រាយថា $q\Rightarrow p$ ពិត ៖

បើ $\alpha=\beta$ នោះយើងត្រូវស្រាយថា $\sin^6\alpha+3\sin^2\alpha\cos^2\alpha+\cos^6\alpha=1$ ពិតគ្រប់ $\alpha\in\left[0,\frac{\pi}{2}\right]$

តាម $a^3+3ab(a+b)+b^3=(a+b)^3$ យក $a=\sin^2\alpha$, $b=\cos^2\alpha$

គេបាន $\sin^6\alpha+3\sin^2\alpha\cos^2\alpha+\cos^6\alpha=1$ ពិត

ដូចនេះ $\sin^6\alpha+3\sin^2\alpha\cos^2\beta+\cos^6\beta=1$ លុះត្រាតែ $\alpha=\beta$

លំហាត់ទី៩៦(APMC 1982)

ចូរស្រាយបញ្ជាក់ថា $\prod_{k=1}^{n}\tan\left[\frac{\pi}{3}\left(1+\frac{3^k}{3^n-1}\right)\right]=\prod_{k=1}^{n}\cot\left[\frac{\pi}{3}\left(1-\frac{3^k}{3^n-1}\right)\right]$

ដំណោះស្រាយ

តាង $a_k=\tan\left[\frac{\pi}{3}\left(1+\frac{3^k}{3^n-1}\right)\right]$ និង $b_k=\tan\left[\frac{\pi}{3}\left(1-\frac{3^k}{3^n-1}\right)\right]$

ដើម្បីស្រាយថា $\prod_{k=1}^{n}(a_k)=\prod_{k=1}^{n}\left(\frac{1}{b_k}\right)$ ពិតយើងគ្រាន់តែស្រាយថា $\prod_{k=1}^{n}(a_kb_k)=1$ ពិត

យក $t_k=\tan\frac{3^{k-1}\pi}{3^n-1}$ នោះគេបាន $a_k=\tan\left[\frac{\pi}{3}\left(1+\frac{3^k}{3^n-1}\right)\right]=\tan\left(\frac{\pi}{3}+\frac{3^{k-1}\pi}{3^n-1}\right)=\frac{\sqrt{3}+t_k}{1-\sqrt{3}t_k}$

និង $b_k=\tan\left[\frac{\pi}{3}\left(1-\frac{3^k}{3^n-1}\right)\right]=\tan\left(\frac{\pi}{3}-\frac{3^{k-1}\pi}{3^n-1}\right)=\frac{\sqrt{3}-t_k}{1+\sqrt{3}t_k}$

គេបាន $a_kb_k=\frac{3-t_k{}^2}{1-3t_k{}^2}=\frac{1}{t_k}\times\frac{3t_k-t_k^3}{1-3t_k{}^2}=\frac{t_{k+1}}{t_k}$ ព្រោះតាមរូបមន្ត $\tan 3\varphi=\frac{3\tan\varphi-\tan^3\varphi}{1-3\tan^2\varphi}$

គេបាន $\frac{3t_k-t_k^3}{1-3t_k{}^2}=t_{k+1}$ ហេតុនេះ $\prod_{k=1}^{n}(a_kb_k)=\prod_{k=1}^{n}\frac{t_{k+1}}{t_k}=\frac{t_2}{t_1}.\frac{t_3}{t_2}\dots\frac{t_{n+1}}{t_n}=\frac{t_{n+1}}{t_1}$

ដោយ $t_k=\tan\frac{3^{k-1}\pi}{3^n-1}$ នោះ $t_1=\tan\frac{\pi}{3^n-1}$ ហើយ $t_{n+1}=\tan\frac{3^n\pi}{3^n-1}=\tan\left(\pi+\frac{\pi}{3^n-1}\right)=\tan\frac{\pi}{3^n-1}$

គេបាន $\prod_{k=1}^{n}(a_kb_k)=\frac{\tan\frac{\pi}{3^n-1}}{\tan\frac{\pi}{3^n-1}}=1$ ពិត

ដូចនេះ $\prod_{k=1}^{n}\tan\left[\frac{\pi}{3}\left(1+\frac{3^k}{3^n-1}\right)\right]=\prod_{k=1}^{n}\cot\left[\frac{\pi}{3}\left(1-\frac{3^k}{3^n-1}\right)\right]$ ។

លំហាត់ទី៩៧(MOSP 2000)

គេឲ្យត្រីកោណ ABC មួយមានមុំក្នុង A,B,C ។

ចូរបង្ហាញថា $\cos^2A+\cos^2B+\cos^2C=1-2\cos A\cos B\cos C$ រួចទាញថាបើ A,B,C ជាមុំស្រួចនោះ គេបាន $\sin^2A+\sin^2B+\sin^2C>2$ ។

ដំណោះស្រាយ

បង្ហាញថា $\cos^2A+\cos^2B+\cos^2C=1-2\cos A\cos B\cos C$

គេមាន $\cos^2A=\frac{1+\cos 2A}{2}$ និង $\cos^2B=\frac{1+\cos 2B}{2}$

គេបាន $\cos^2A+\cos^2B=1+\frac{\cos 2A+\cos 2B}{2}$

ដោយ $\cos 2A+\cos 2B=2\cos(A+B)\cos(A-B)=2\cos(\pi-C)\cos(A-B)=-2\cos C\cos(A-B)$

នោះ $\cos^2A+\cos^2B=1-\cos C\cos(A-B)$

$$\cos^2A+\cos^2B+\cos^2C=1-\cos C\cos(A-B)+\cos^2C$$

$$\cos^2A+\cos^2B+\cos^2C=1-\cos C\left[\cos(A-B)-\cos C\right]$$

$$=1-\cos C\left[\cos(A-B)+\cos(A+B)\right]=1-2\cos A\cos B\cos C$$

ដូចនេះ $\cos^2A+\cos^2B+\cos^2C=1-2\cos A\cos B\cos C$

ទាញថាបើ A,B,C ជាមុំស្រួចនោះ $\sin^2A+\sin^2B+\sin^2C>2$

គេមាន $\cos^2A+\cos^2B+\cos^2C=1-2\cos A\cos B\cos C$

តាមរូបមន្ត $\cos^2\varphi = 1-\sin^2\varphi$ នោះគេបាន $3-(\sin^2 A+\sin^2 B+\sin^2 C)=1-2\cos A\cos B\cos C$

គេទាញ $\sin^2 A+\sin^2 B+\sin^2 C = 2+2\cos A\cos B\cos C$

បើ A,B,C ជាមុំស្រួចនោះ $\begin{cases}\cos A>0\\ \cos B>0\\ \cos C>0\end{cases}$ នាំឲ្យ $2+2\cos A\cos B\cos C>2$ ។

ដូចនេះបើ A,B,C ជាមុំស្រួចនោះ $\sin^2 A+\sin^2 B+\sin^2 C>2$ ។

លំហាត់ទី៩៨

គេឲ្យត្រីកោណ ABC មួយមានមុំក្នុង A,B,C ។

ចូរបង្ហាញថា $\cos A+\sqrt{2}(\cos B+\cos C)\le 2$ ។

ដំណោះស្រាយ

បង្ហាញថា $\cos A+\sqrt{2}(\cos B+\cos C)\le 2$

$$\cos A+\sqrt{2}(\cos B+\cos C)=1-2\sin^2\frac{A}{2}+2\sqrt{2}\cos\frac{B+C}{2}\cos\frac{B-C}{2}$$

ដោយ $\cos\frac{B+C}{2}=\cos\left(\frac{\pi}{2}-\frac{A}{2}\right)=\sin\frac{A}{2}$ និង $\cos\frac{B-C}{2}\le 1$

គេបាន $\cos A+\sqrt{2}(\cos B+\cos C)\le 1-2\sin^2\frac{A}{2}+2\sqrt{2}\sin\frac{A}{2}$

ដោយ $1-2\sin^2\frac{A}{2}+2\sqrt{2}\sin\frac{A}{2}=2-2\left(\sin\frac{A}{2}-\frac{\sqrt{2}}{2}\right)^2\le 2$

ដូច្នេះ $\cos A+\sqrt{2}(\cos B+\cos C)\le 2$ ។

លំហាត់ទី៩៩

គេឲ្យត្រីកោណ ABC មួយមានមុំក្នុង A,B,C ។ ចូរបង្ហាញថា $\cot A+\cot B+\cot C\ge\sqrt{3}$ ។

ដំណោះស្រាយ

គេមាន $\cot A+\cot B=\frac{\sin(A+B)}{\sin A\sin B}=\frac{2\sin C}{\cos(A-B)+\cos C}$ ដោយ $\cos(A-B)\le 1$

នោះ $\cot A+\cot B\ge\frac{2\sin C}{1+\cos C}=2\tan\frac{C}{2}$

$$\cot A+\cot B+\cot C\ge 2\tan\frac{C}{2}+\cot C=2\tan\frac{C}{2}+\frac{\cot^2\frac{C}{2}-1}{2\cot\frac{C}{2}}$$

$\cot A+\cot B+\cot C\ge\frac{\cot^2\frac{C}{2}+3}{2\cot\frac{C}{2}}=\frac{1}{2}\left(\cot\frac{C}{2}+3\tan\frac{C}{2}\right)$ ដោយ $\cot\frac{C}{2}+3\tan\frac{C}{2}\ge\sqrt{3}$ (តាម $AM-GM$) ។

ដូចនេះ $\cot A+\cot B+\cot C\ge\sqrt{3}$ ។

លំហាត់ទី១០០

គេឲ្យត្រីកោណ ABC មួយមានមុំក្នុងជាមុំស្រួច និងមានជ្រុង $BC=a, AC=b, AB=c$ ។

បើ $a<\frac{b+c}{2}$ នោះបង្ហាញថាមុំ $A<\frac{B+C}{2}$ ។

ដំណោះស្រាយ

តាមទ្រស្តីបទស៊ីនូស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=2R$ នោះ $\begin{cases} a=2R\sin A \\ b=2R\sin B \\ c=2R\sin C \end{cases}$

វិសមមភាព $a<\frac{b+c}{2}$ សមមូល $2R\sin A<R\sin B+R\sin C$

ឬ $\sin A<\frac{\sin B+\sin C}{2}=\sin\frac{B+C}{2}\cos\frac{B-C}{2}\le\sin\frac{B+C}{2}$ ដោយ A និង $\frac{B+C}{2}$ ជាមុំស្រួចនោះ $A<\frac{B+C}{2}$ ។

ដូចនេះ បើ $a<\frac{b+c}{2}$ នោះ $A<\frac{B+C}{2}$ ។

លំហាត់ទី១០១

ត្រីកោណ ABC មួយមានមានជ្រុង $BC=a, AC=b, AB=c$ ។ តាង S ជាផ្ទៃក្រលានៃត្រីកោណ ។

ក) ចូរស្រាយថា $\cos(\frac{\pi}{3}-A)=\frac{b^2+c^2-a^2+4S\sqrt{3}}{4bc}$

ខ) ទាញឲ្យបានថា $a^2+b^2+c^2\ge 4\sqrt{3}S$ ។

ដំណោះស្រាយ

ក) ស្រាយថា $\cos(\frac{\pi}{3}-A)=\frac{b^2+c^2-a^2+4S\sqrt{3}}{4bc}$

តាមទ្រឹស្តីបទកូស៊ីនូស $a^2=b^2+c^2-2bc\cos A$ គេទាញបាន $b^2+c^2-a^2=2bc\cos A$ ហើយ $S=\frac{1}{2}bc\sin A$

គេបាន $b^2+c^2-a^2+4\sqrt{3}S=2bc\cos A+2\sqrt{3}bc\sin A=4bc(\frac{1}{2}\cos A+\frac{\sqrt{3}}{2}\sin A)=4bc\cos\left(\frac{\pi}{3}-A\right)$

ដូចនេះ $\cos(\frac{\pi}{3}-A)=\frac{b^2+c^2-a^2+4S\sqrt{3}}{4bc}$ ។

ខ) ទាញឲ្យបានថា $a^2+b^2+c^2\ge 4\sqrt{3}S$

គេមាន $\cos(\frac{\pi}{3}-A)=\frac{b^2+c^2-a^2+4S\sqrt{3}}{4bc}$ ដោយ $\cos\left(\frac{\pi}{3}-A\right)\le 1$ នោះ $\frac{b^2+c^2-a^2+4S\sqrt{3}}{4bc}\le 1$

គេទាញ $4bc\ge b^2+c^2-a^2+4S\sqrt{3}$ សមមូល $a^2+b^2+c^2\ge 2(b-c)^2+4\sqrt{3}S$ ដោយ $(b-c)^2\ge 0$

ដូចនេះ $a^2+b^2+c^2\ge 4\sqrt{3}S$ ។

លំហាត់ទី១០២

គេឲ្យត្រីកោណ ABC មួយកែងត្រង់ A ។ តាងជ្រុង $BC=a\,,AC=b$ និង $AB=c$ ។

ចូរស្រាយថា $\cos^2\dfrac{B-C}{2}\geq\dfrac{2bc}{a^2}$?

ដំណោះស្រាយ

ស្រាយថា $\cos^2\dfrac{B-C}{2}\geq\dfrac{2bc}{a^2}$

សន្មតថា $B\neq C$ នោះតាមវិសមភាព $AM-GM$ គេមាន $\dfrac{\sin B+\sin C}{2}\geq\sqrt{\sin B\sin C}$

ឬ $\sin\dfrac{B+C}{2}\cos\dfrac{B-C}{2}\geq\sqrt{\sin B\sin C}$ ដោយ $\sin\dfrac{B+C}{2}=\sin\dfrac{\pi}{4}=\dfrac{\sqrt{2}}{2}$ និង $\sin B=\dfrac{b}{a}\,,\ \sin C=\dfrac{c}{a}$

គេបាន $\dfrac{\sqrt{2}}{2}\cos\dfrac{B-C}{2}\geq\sqrt{\dfrac{bc}{a^2}}$ សមមូល $\cos^2\dfrac{B-C}{2}\geq\dfrac{2bc}{a^2}$ ពិត។

លំហាត់ទី១០៣

គេឲ្យត្រីកោណ ABC មួយមានមុំ $A>\dfrac{\pi}{2}$ ។ តាងជ្រុង $BC=a\,,AC=b$ និង $AB=c$ ។

ចូរស្រាយថា $|\cos A|\leq\dfrac{a^6}{54b^3c^3}$?

ដំណោះស្រាយ

ស្រាយថា $|\cos A|\leq\dfrac{a^6}{54b^3c^3}$

បើ $A>\dfrac{\pi}{2}$ នោះ $\cos A=-|\cos A|$ ។

តាមទ្រឹស្តីបទស៊ីនូសគេបាន $a^2=b^2+c^2-2bc\cos A=b^2+c^2+2bc|\cos A|$

តាមវិសមភាព $AM-GM$ គេបាន $a^2=b^2+c^2+2bc|\cos A|\geq 3\sqrt[3]{2b^3c^3.|\cos A|}$

គេទាញ $|\cos A|\leq\dfrac{a^6}{54b^3c^3}$ ពិត ។

លំហាត់ទី១០៤

គេឲ្យត្រីកោណ ABC មួយ ។ P ជាចំណុចនៅក្នុង ΔABC ដែល $\angle PAB=\angle PBC=\angle PCA=\omega$ ។

ក) ចូរស្រាយថា $\cot\omega=\cot A+\cot B+\cot C$ ។

ខ) ទាញឲ្យបានថា $\omega\leq\dfrac{\pi}{6}$ ។

ដំណោះស្រាយ

ក) ស្រាយថា $\cot\omega=\cot A+\cot B+\cot C$

តាង $BC=a\,,\ AC=b\,,\ AB=c\,,PA=x\,,PB=y\,,PC=z$

តាមទ្រឹស្តីបទកូស៊ីនូសអនុវត្តន៍ក្នុង ΔPAB ,ΔPBC ,ΔPCA គេបាន $\begin{cases} x^2 = z^2 + b^2 - 2bz\cos\omega \\ y^2 = x^2 + c^2 - 2cx\cos\omega \\ z^2 = y^2 + a^2 - 2ay\cos\omega \end{cases}$

បូកសមីការបីនេះអង្គ និង អង្គគេបាន $x^2 + y^2 + z^2 = x^2 + y^2 + z^2 + a^2 + b^2 + c^2 - 2(ay + bz + cx)\cos\omega$

គេទាញ $\cos\omega = \dfrac{a^2 + b^2 + c^2}{2(ay + bz + cx)}$ (1)

គេមាន $S_{ABC} = S_{PAB} + S_{PBC} + S_{PCA}$ ដោយ $\begin{cases} S_{PAB} = \dfrac{1}{2}cx\sin\omega \\ S_{PBC} = \dfrac{1}{2}ay\sin\omega \\ S_{PCA} = \dfrac{1}{2}bz\sin\omega \end{cases}$

គេបាន $S_{ABC} = \dfrac{1}{2}(cx + ay + bz)\sin\omega$ គេទាញ $\sin\omega = \dfrac{2S_{ABC}}{cx + ay + bz}$ (2)

ធ្វើផលចែករវាង (1) និង (2) គេបាន $\cot\omega = \dfrac{a^2 + b^2 + c^2}{4S_{ABC}}$ (3)

ម្យ៉ាងទៀតតាមទ្រឹស្តីបទកូស៊ីនូសគេមាន $a^2 = b^2 + c^2 - 2bc\cos A$

គេទាញ $\cos A = \dfrac{b^2 + c^2 - a^2}{2bc}$ ហើយ $S_{ABC} = \dfrac{1}{2}bc\sin A$

គេទាញ $\sin A = \dfrac{2S_{ABC}}{bc}$ ។ ហេតុនេះ $\cot A = \dfrac{b^2 + c^2 - a^2}{4S}$

ដូចគ្នាដែរ $\cot B = \dfrac{c^2 + a^2 - b^2}{2ca}$, $\cot C = \dfrac{a^2 + b^2 - c^2}{2ab}$

គេបាន $\cot A + \cot B + \cot C = \dfrac{a^2 + b^2 + c^2}{4S_{ABC}}$ (4)

តាម (3) និង (4) គេបាន $\cot\omega = \cot A + \cot B + \cot C$ ពិត

ខ) ទាញឲ្យបានថា $\omega \le \dfrac{\pi}{6}$

គេមាន $\cot\omega = \cot A + \cot B + \cot C$

ដោយ $\cot A + \cot B + \cot C \ge \sqrt{3}$ (មើលលំហាត់ទី៩៩)

គេបាន $\cot\omega \ge \sqrt{3} = \cot\dfrac{\pi}{6}$ នាំឲ្យ $\omega \le \dfrac{\pi}{6}$ ។

លំហាត់ទី១០៥(IMO1966)

គេឲ្យត្រីកោណ ABC មួយមានជ្រុង $BC = a, AC = b, AB = c$ ។

ចូរបង្ហាញថាបើ $a + b = \tan\dfrac{C}{2}\left(a\tan A + b\tan B\right)$ នោះ ABC ជាត្រីកោណសមបាត ។

ដំណោះស្រាយ

តាង $u=\tan\frac{A}{2}$ និង $v=\tan\frac{C}{2}$

គេបាន $\tan\frac{C}{2}=\tan\left(\frac{\pi}{2}-\frac{A+B}{2}\right)=\cot\frac{A+B}{2}=\frac{1-uv}{u+v}$ ហើយ $\tan A=\frac{2u}{1-u^2}$, $\tan B=\frac{2v}{1-v^2}$ ។

តាមទ្រឹស្តីបទស៊ីនូស $a=2R\sin A=2R\frac{2u}{1+u^2}$, $b=2R\frac{2v}{1+v^2}$ ដែល R ជាកាំរង្វង់ចារឹកក្រៅនៃត្រីកោណ ។

សមភាព $a+b=\tan\frac{C}{2}(a\tan A+b\tan B)$ សមមូល ៖

$$4R\left(\frac{u}{1+u^2}+\frac{v}{1+v^2}\right)=4R\frac{1-uv}{u+v}\left(\frac{u^2}{(1+u^2)(1-u^2)}+\frac{v^2}{(1+v^2)(1-v^2)}\right)$$

បន្ទាប់ពីបង្រួមគេបាន $(u+v)^2(1-u^2)(1-v^2)=2(1-uv)^2(u^2+v^2)$

គេមាន $(u+v)^2\le 2(u^2+v^2)$ (1) (វិសមភាព $Cauchy-Schwarz$)

$(1-u^2)(1-v^2)=(1-uv)^2-(u-v)^2\le(1-uv)^2$ (2)

គុណវិសមភាព(1)និង(2) អង្គ និង អង្គគេបាន $(u+v)^2(1-u^2)(1-v^2)\le 2(1-uv)^2(u^2+v^2)$

ដើម្បីឲ្យវិសមភាពនេះក្លាយជាសមភាពលុះត្រាតែ (1) និង (2) ក្លាយជាសមភាពពោលគឺគេត្រូវឲ្យ $u=v$

នោះ $\tan\frac{A}{2}=\tan\frac{B}{2}$ សមមូល $A=B$ សមមូល $a=b$ ។

ដូចនេះបើ $a+b=\tan\frac{C}{2}(a\tan A+b\tan B)$ នោះ ABC ជាត្រីកោណសមបាត ។

លំហាត់ទី១០៦

គេឲ្យត្រីកោណ ABC មួយមានជ្រុង a,b,c ។

ក) ចូរស្រាយថា $1+\cos A\cos B\cos C=\frac{a^2+b^2+c^2}{8R^2}$ ដែល R ជាកាំរង្វង់ចារឹកក្រៅនៃត្រីកោណ ។

ខ) ទាញឲ្យបានថា $a^2+b^2+c^2\le 9R^2$ ។

ដំណោះស្រាយ

ក) ស្រាយថា $1+\cos A\cos B\cos C=\frac{a^2+b^2+c^2}{8R^2}$

តាមទ្រឹស្តីបទស៊ីនូស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=2R$ ដែល R ជាកាំរង្វង់ចារឹកក្រៅនៃត្រីកោណ ។

គេបាន $a^2+b^2+c^2=4R^2(\sin^2 A+\sin^2 B+\sin^2 c)$

គេទាញ $\sin^2 A+\sin^2 B+\sin^2 C=\frac{a^2+b^2+c^2}{4R^2}$ (1)

យើងនឹងស្រាយថា $\sin^2 A+\sin^2 B+\sin^2 C=2+2\cos A\cos B\cos C$

គេមាន $\sin^2 A=\frac{1-\cos 2A}{2}$ និង $\sin^2 B=\frac{1-\cos 2B}{2}$

គេបាន $\sin^2 A+\sin^2 B=1-\frac{\cos 2A+\cos 2B}{2}$

$$=1-\cos(A+B)\cos(A-B)$$
$$=1-\cos(\pi-C)\cos(A-B)$$
$$=1+\cos C\cos(A-B)$$

ហើយ $\sin^2 C=1-\cos^2 C$ នោះគេបាន $\sin^2 A+\sin^2 B+\sin^2 C=2+\cos C\cos(A-B)-\cos^2 C$

$$=2+\cos C\left[\cos(A-B)-\cos C\right]$$
$$=2+\cos C\left[\cos(A-B)+\cos(A+B)\right]$$
$$=2+2\cos A\cos B\cos C$$

ដូចនេះ $1+\cos A\cos B\cos C=\dfrac{a^2+b^2+c^2}{8R^2}$ ។

ខ) ទាញឲ្យបានថា $a^2+b^2+c^2\le 9R^2$

តាមទ្រឹស្តីបទកូស៊ីនូស $\cos A=\dfrac{b^2+c^2-a^2}{2bc}$, $\cos B=\dfrac{c^2+a^2-b^2}{2ca}$ និង $\cos C=\dfrac{a^2+b^2-c^2}{2ab}$ ។

គេបាន $\cos A\cos B\cos C=\dfrac{(b^2+c^2-a^2)(c^2+a^2-b^2)(a^2+b^2-c^2)}{8a^2b^2c^2}$

តាង $\begin{cases}x=b^2+c^2-a^2\\ y=c^2+a^2-b^2\\ z=a^2+b^2-c^2\end{cases}$ នោះ $\begin{cases}x+y=2c^2\\ y+z=2a^2\\ z+x=2b^2\end{cases}$

គេបាន $\cos A\cos B\cos C=\dfrac{xyz}{(x+y)(y+z)(z+x)}$

តាមវិសមភាព $AM-GM$ គេមាន $\begin{cases}x+y\ge 2\sqrt{xy}\\ y+z\ge 2\sqrt{yz}\\ z+x\ge 2\sqrt{zx}\end{cases}$

នាំឲ្យ $(x+y)(y+z)(z+x)\ge 2\sqrt{xy}.2\sqrt{yz}.2\sqrt{zx}=8xyz$

គេទាញ $\cos A\cos B\cos C=\dfrac{xyz}{(x+y)(y+z)(z+x)}\le\dfrac{1}{8}$

គេទាញ $\dfrac{a^2+b^2+c^2}{8R^2}=1+\cos A\cos B\cos C\le 1+\dfrac{1}{8}=\dfrac{9}{8}$

ដូចនេះ $a^2+b^2+c^2\le 9R^2$ ។

លំហាត់ទី១០៧(IMO 1977)

គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=1-a\cos x-b\sin x-A\cos 2x-B\sin 2x$

ដែល a,b,A,B ជាចំនួនពិត ។ចូរស្រាយថាបើគ្រប់ $x\in IR$: $f(x)\ge 0$ នោះ $a^2+b^2\le 2$

និង $A^2+B^2\le 1$ ។

ដំណោះស្រាយ

តាង $r=\sqrt{a^2+b^2}$ និង $R=\sqrt{A^2+B^2}$ ហើយយក α និង β ដែល $\cos\alpha=\dfrac{a}{r}$, $\sin\alpha=\dfrac{b}{r}$

និង $\cos 2\beta=\dfrac{A}{R}$, $\sin 2\beta=\dfrac{B}{R}$ ។

គេបាន $f(x)=1-a\cos x-b\sin x-A\cos 2x-B\sin 2x$

$=1-r\cos(x-\alpha)-R\cos(2x-2\beta)$

គេមាន $f(\beta)=1-r\cos(\beta-\alpha)-R$ និង $f(\pi+\beta)=1-r\cos(\pi+\beta-\alpha)-R=1+r\cos(\beta-\alpha)-R$

គេបាន $f(\beta)+f(\pi+\beta)=2-2R\ge 0$ នោះ $R\le 1$

សមមូល $\sqrt{A^2+B^2}\le 1$ ឬ $A^2+B^2\le 1$ ។

គេមាន $f(\alpha+\frac{\pi}{4})=1-r\frac{\sqrt{2}}{2}+R\sin(2\alpha-2\beta)$ និង $f(\alpha-\frac{\pi}{4})=1-r\frac{\sqrt{2}}{2}R\sin(2\alpha-2\beta)$

គេបាន $f(\alpha+\frac{\pi}{4})+f(\alpha-\frac{\pi}{4})=2-\sqrt{2}r\ge 0$ នោះ $r\le\sqrt{2}$

សមមូល $\sqrt{a^2+b^2}\le 2$ ឬ $a^2+b^2\le 2$ ។

ដូចនេះបើគ្រប់ $x\in IR:\ f(x)\ge 0$ នោះ $a^2+b^2\le 2$ និង $A^2+B^2\le 1$ ។

លំហាត់ទី១០៨

គេឲ្យត្រីកោណ ABC មួយ ។ ចូរស្រាយថា $A\le\frac{\pi}{3}$ លុះត្រាតែ $(p-b)(p-c)\le\frac{bc}{4}$

ដែល a,b,c ជាជ្រុង និង $p=\frac{a+b+c}{2}$ ។

ដំណោះស្រាយ

យើងមាន $A\le\frac{\pi}{3}$ សមមូល $\sin\frac{A}{2}\le\sin\frac{\pi}{6}=\frac{1}{2}$ សមមូល $\sin^2\frac{A}{2}\le\frac{1}{4}$ ដោយ $\sin^2\frac{A}{2}=\frac{1-\cos A}{2}$

សមមូល $\frac{1-\cos A}{2}\le\frac{1}{4}$ សមមូល $\cos A\ge\frac{1}{2}$ ដោយ $\cos A=\frac{b^2+c^2-a^2}{2bc}$ (ទ្រឹស្តីបទកូស៊ីនូស)

គេបាន $\frac{b^2+c^2-a^2}{2bc}\ge\frac{1}{2}$ សមមូល $b^2+c^2-a^2\ge bc$ សមមូល $a^2-(b-c)^2=(a-b+c)(a+b-c)\le bc$

សមមូល $4(p-b)(p-c)\le bc$ ឬ $(p-b)(p-c)\le\frac{bc}{4}$ ពិត ។

លំហាត់ទី១០៩

គេឲ្យត្រីកោណ ABC មួយមានជ្រុង a,b,c ។ ចូររកប្រភេទនៃត្រីកោណនេះដោយដឹងថា $\sin\frac{A}{2}=\frac{a}{2\sqrt{bc}}$ ។

ដំណោះស្រាយ

រកប្រភេទនៃត្រីកោណនេះ

គេមាន $\sin\frac{A}{2}=\frac{a}{2\sqrt{bc}}$ នោះ $\sin^2\frac{A}{2}=\frac{a^2}{4bc}$ ដោយ $\sin^2\frac{A}{2}=\frac{1-\cos A}{2}$ និង $\cos A=\frac{b^2+c^2-a^2}{2bc}$

គេបាន $\frac{1-\frac{b^2+c^2-a^2}{2bc}}{2}=\frac{a^2}{4bc}$ សមមូល $\frac{2bc-b^2-c^2+a^2}{2bc}=\frac{a^2}{2bc}$

$-(b-c)^2=0$ នាំឲ្យ $b=c$

ដូចនេះ ABC ជាត្រីកោណសមបាតកំពូល A ។

លំហាត់ទី១១០

ក្នុងគ្រប់ត្រីកោណ ABC ចូរស្រាយថា $\dfrac{\sin B}{\sin^2\frac{C}{2}}+\dfrac{\sin C}{\sin^2\frac{B}{2}}\ge\dfrac{4\cos\frac{A}{2}}{1-\sin\frac{A}{2}}$

ដំណោះស្រាយ

ស្រាយថា $\dfrac{\sin B}{\sin^2\frac{C}{2}}+\dfrac{\sin C}{\sin^2\frac{B}{2}}\ge\dfrac{4\cos\frac{A}{2}}{1-\sin\frac{A}{2}}$

តាង $a\,,b,c$ ជាជ្រុងនៃ ΔABC និង $p=\dfrac{a+b+c}{2}$ ជាកន្លះបរិមាត្រ

គេមាន $S=\dfrac{1}{2}ac\sin B=\dfrac{1}{2}ab\sin C$ (S ជាផ្ទៃក្រលាត្រីកោណ)

គេបាន $\sin B=\dfrac{2S}{ac}$ និង $\sin C=\dfrac{2S}{ab}$ ។ ហើយ $\sin\dfrac{A}{2}=\sqrt{\dfrac{(p-b)(p-c)}{bc}}$, $\sin\dfrac{B}{2}=\sqrt{\dfrac{(p-a)(p-c)}{ac}}$

$\sin\dfrac{A}{2}=\sqrt{\dfrac{(p-a)(p-b)}{ab}}$ និង $\cos\dfrac{A}{2}=\sqrt{\dfrac{p(p-a)}{bc}}$ ។

វិសមភាពសមមូល ៖

$$\frac{\frac{2S}{ac}}{\frac{(p-b)(p-a)}{ab}}+\frac{\frac{2S}{ab}}{\frac{(p-c)(p-a)}{ac}}\ge 4\,\frac{\sqrt{\frac{p(p-a)}{bc}}}{1-\sqrt{\frac{(p-b)(p-c)}{bc}}}$$

$$\frac{2S}{p-a}\left[\frac{b}{c(p-b)}+\frac{c}{b(p-c)}\right]\ge\frac{\sqrt{p(p-a)}}{\sqrt{bc}-\sqrt{(p-b)(p-c)}}$$

ដោយ $S=\sqrt{p(p-a)(p-b)(p-c)}$ នោះគេបាន ៖

$$\frac{\sqrt{(p-b)(p-c)}}{p-a}\left[\frac{b}{c(p-b)}+\frac{c}{b(p-c)}\right]\ge 2\,\frac{\sqrt{bc}+\sqrt{(p-b)(p-c)}}{p(p-a)}$$

$$p\sqrt{(p-b)(p-c)}\left[\frac{b}{c(p-b)}+\frac{c}{b(p-c)}\right]\ge 2\left(\sqrt{bc}+\sqrt{(p-b)(p-c)}\right)$$

តាមវិសមភាព $AM-GM$ គេមាន $\sqrt{(p-b)(p-c)}\left[\dfrac{b}{c(p-b)}+\dfrac{c}{b(p-c)}\right]\ge 2$

និង $p\ge\sqrt{bc}+\sqrt{(p-b)(p-c)}$ នោះគេបានវិសមភាពខាងលើពិត ។

លំហាត់ទី១១១

គេតាង r និង R រៀងគ្នាជារង្វាស់កាំនៃរង្វង់ចារឹកក្នុង និងកាំរង្វង់ចារឹកក្រៅនៃ ΔABC មួយ ។

ចូរស្រាយបញ្ជាក់ថា $\dfrac{1}{\sin^2 A}+\dfrac{1}{\sin^2 B}+\dfrac{1}{\sin^2 C}\le\dfrac{R^2}{r^2}$

ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $\dfrac{1}{\sin^2 A}+\dfrac{1}{\sin^2 B}+\dfrac{1}{\sin^2 C}\le\dfrac{R^2}{r^2}$

តាង $BC=a$, $AC=b$, $AB=c$ ជាជ្រុងនៃត្រីកោណនិង $p=\dfrac{a+b+c}{2}$ ជាកន្លះបរិមាត្រនៃត្រីកោណ ។

តាមទ្រឹស្តីបទស៊ីនូស $\dfrac{a}{\sin A}=\dfrac{b}{\sin B}=\dfrac{c}{\sin C}=2R$ គេទាញ $\dfrac{1}{\sin A}=\dfrac{2R}{a}$, $\dfrac{1}{\sin B}=\dfrac{2R}{b}$, $\dfrac{1}{\sin C}=\dfrac{2R}{c}$

វិសមភាពសមមូល $4R^2\left(\dfrac{1}{a^2}+\dfrac{1}{b^2}+\dfrac{1}{c^2}\right)\le\dfrac{R^2}{r^2}$ សមមូល $\dfrac{1}{a^2}+\dfrac{1}{b^2}+\dfrac{1}{c^2}\le\dfrac{1}{4r^2}$

តាមរូបមន្តហេរ៉ុង $S=pr=\sqrt{p(p-a)(p-b)(p-c)}$

គេទាញ $r=\sqrt{\dfrac{(p-a)(p-b)(p-c)}{p}}$

គេបាន $\dfrac{1}{a^2}+\dfrac{1}{b^2}+\dfrac{1}{c^2}\le\dfrac{p}{4(p-a)(p-b)(p-c)}$ (*)

តាង $a=y+z$, $b=x+z$, $c=x+y$ គេបាន $a+b+c=2(x+y+z)=2p$

នោះ $x+y+z=p$ ហើយ $\begin{cases}p-a=x\\p-b=y\\p-c=z\end{cases}$

វិសមភាព (*) សមមូល $\dfrac{1}{(y+z)^2}+\dfrac{1}{(x+z)^2}+\dfrac{1}{(x+y)^2}\le\dfrac{x+y+z}{4xyz}$ (**)

តាមវិសមភាព AM-GM គេមាន $(y+z)^2\ge 4yz$ នោះ $\dfrac{1}{(y+z)^2}\le\dfrac{1}{4yz}=\dfrac{x}{4xyz}$ (1)

ដូចគ្នាដែរ $\dfrac{1}{(z+x)^2}\le\dfrac{y}{4xyz}$ (2) ; $\dfrac{1}{(x+y)^2}\le\dfrac{z}{4xyz}$ (3)

បូកវិសមភាព(1),(2) និង (3) នោះ (**) ពិត